# ព្រះរាជក្រម

នស/រកម/១០០៧/០២៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភានីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

143

# ច្បាប់

# ស្តីពី

# ការបោះផ្សាយ

# និង

# ការជួញដូរមូលបត្រមហាជន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.– គោលដៅ**

ច្បាប់នេះមានគោលដៅគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រដែលធ្វើការជួញដូរ ឬ ផ្តល់សេវាកម្មហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិ-បុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រ ។ ច្បាប់នេះរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពីសាធារណជន ឬ អ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ សម្រាប់ការវិនិយោគ ។

**មាត្រា ២.– គោលបំណង**

ច្បាប់នេះមានគោលបំណង :

១-បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ ។

២-លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ។

៣-ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូល-បត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ។

៤-ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូល-បត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥-ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

**មាត្រា ៣.- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការមូលបត្រមហាជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២

## គណៈកម្មការមូលបត្រកម្ពុជា

**មាត្រា ៥.- អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា**

គណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ត្រូវបានបង្កើតឡើងដោយច្បាប់នេះ ដែលមានប្រធាន ១(មួយ)រូប និងសមាជិកចំនួន ៨(ប្រាំបី)រូប ដែលតែងតាំងដោយអនុក្រឹត្យ ។ សមាជិករបស់**គ.ម.ក.** មានអាណត្តិ ៥(ប្រាំ)ឆ្នាំ ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬ ផ្លាស់ប្តូរភារកិច្ច ។ សមាជិក**គ.ម.ក.** អាចត្រូវបានតែងតាំងសារជាថ្មីទៀតបាន តាមសំណើរបស់ប្រធាន**គ.ម.ក.** នៅពេលផុតអាណត្តិ ។

**មាត្រា ៦.- សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា**

ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សមាសភាពរបស់**គ.ម.ក.** មាន :

១- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ (មួយ)រូប

២- តំណាងធនាគារជាតិនៃកម្ពុជា ០១ (មួយ)រូប

៣- តំណាងក្រសួងពាណិជ្ជកម្ម ០១ (មួយ)រូប

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៤- តំណាងក្រសួងយុត្តិធម៌ ០១ (មួយ)រូប

៥- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ០១ (មួយ)រូប

៦- អគ្គនាយក **គ.ម.ក.** ០១ (មួយ)រូប

៧- អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២ (ពីរ)រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បេក្ខភាពរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល ។ សមាជិកនៃ **គ.ម.ក.** ដែលជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព និងលក្ខណៈ-សម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនព្រមទាំងមានបទពិសោធន៍មួយ ឬ ច្រើនផ្នែក ដូចជាពាណិជ្ជកម្ម គ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណ-នេយ្យ និងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្ដែង ។

## មាត្រា ៧.- មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ ។

២-ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ ។

៣-កំណត់លក្ខខណ្ឌ ដើម្បីផ្ដល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ។

៤-កំណត់លក្ខខណ្ឌដើម្បីផ្ដល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ។

៥-លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ ។

៦-ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្ដីសម្រេចរបស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ ។

៧-ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៨-បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ ។

## មាត្រា ៨.- មុខងាររបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា

អគ្គនាយកនៃ **គ.ម.ក.** មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រងបុគ្គលិក និងមន្ត្រីជំនាញដែលទទួលបន្ទុកសម្របសម្រួលកិច្ចការរដ្ឋបាលរបស់**គ.ម.ក.** ក្នុងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-រាយការណ៍ និងផ្តល់អនុសាសន៍ជូនប្រធាន និងសមាជិកទាំងអស់នៃ **គ.ម.ក.** នូវរាល់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការអភិវឌ្ឍ និង ការត្រួតពិនិត្យទីផ្សារមូល-បត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការលើកសំណើសុំធ្វើវិសោធនកម្មច្បាប់ និងបទ-ប្បញ្ញត្តិផ្សេងៗ ។

៣-ពិនិត្យសំណុំឯកសារ ដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈនិងផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.** ។

៤-ពិនិត្យឯកសារផ្តល់ព័ត៌មាន ដែលទាក់ទងនឹងសំណើដាក់លក់មូលបត្រមហាជនដែលដាក់មក **គ.ម.ក.** ដើម្បីធានានូវការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ និងបញ្ញត្តិនានានៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដោយផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារដែលបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ ។

៥-ត្រួតពិនិត្យឯកសារផ្តល់ព័ត៌មានជាប្រចាំ ដែលផ្តល់ជូនទីផ្សារមូលបត្រនូវ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

ព័ត៌មានហិរញ្ញវត្ថុ ព័ត៌មានមិនមែនហិរញ្ញវត្ថុ និងព័ត៌មានផ្សេងទៀតរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិយោគសាធារណៈ ។

៦-ត្រួតពិនិត្យការអនុវត្តច្បាប់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនិងនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជូនអ្នកវិនិយោគសាធារណៈ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលច្បាប់តម្រូវ និងចាត់វិធានការអនុវត្តសមស្របណាមួយ ចំពោះអំពើល្មើសនឹងច្បាប់នេះ ។

៧-ទាក់ទងនឹងទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ និងសេវារក្សាទុកមូលបត្រ អគ្គនាយក**គ.ម.ក.** ត្រូវ :

ក-ពិនិត្យ និងពិនិត្យឡើងវិញលើពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់ការអនុញ្ញាត នៅពេលដែលអ្នកស្នើសុំបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.ក.** បានកំណត់ ។

ខ-ពិនិត្យ និងពិនិត្យឡើងវិញ និងផ្តល់ការអនុញ្ញាតឱ្យធ្វើការកែប្រែលើវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ និងសេវារក្សាទុកមូលបត្រ ដែលទទួលបានការអនុញ្ញាត ។

គ-ត្រួតពិនិត្យសកម្មភាពរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីធានាការគោរពតាមលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត និងលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.ក.** បានកំណត់ ។

ឃ-ធ្វើការស៊ើបអង្កេតករណីសង្ស័យ ចំពោះអំពើល្មើសរបស់បុគ្គលដែលទទួលបានការអនុញ្ញាតទៅនឹងលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាត ឬ លក្ខខណ្ឌដែលច្បាប់តម្រូវ និងចាត់វិធានការអនុវត្តសមស្របណាមួយរួមមានការព្យួរ ឬ ការដកហូតការអនុញ្ញាត ។

ង-មុនផ្តល់ការអនុញ្ញាត ឬ ដកហូតការអនុញ្ញាត អគ្គនាយកត្រូវសុំការ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ពិគ្រោះយោបល់ពីការប្រជុំពេញអង្គរបស់ **គ.ម.ក.** ។

៨-ទាក់ទងនឹងក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ អគ្គនាយកនៃ **គ.ម.ក.** ត្រូវ ៖

ក-ពិនិត្យពាក្យស្នើសុំអាជ្ញាប័ណ្ណ និងផ្តល់អាជ្ញាប័ណ្ណ ប្រសិនបើអ្នកស្នើសុំបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងទៀតដែល **គ.ម.ក.** បានកំណត់ ។

ខ-ត្រួតពិនិត្យសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ ក្នុងការគោរពតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណរួមទាំងលក្ខខណ្ឌហិរញ្ញវត្ថុ ។

គ-ត្រួតពិនិត្យការគោរពតាមលក្ខខណ្ឌនៃអាជីវកម្មដែលកំណត់ក្នុងច្បាប់នេះ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

ឃ-ពិនិត្យដើម្បីផ្តល់ការអនុញ្ញាតចំពោះការស្នើសុំឱ្យក្លាយទៅជាស្វ័យនិយ័តករចំពោះពាណិជ្ជករមូលបត្រ ឬ ទីប្រឹក្សាវិនិយោគ ប្រសិនបើអ្នកស្នើសុំនោះបានគោរពតាមលក្ខខណ្ឌដែលបានកំណត់ ។

ង-ត្រួតពិនិត្យការអនុវត្តតាមលក្ខខណ្ឌនៃច្បាប់របស់ស្វ័យនិយ័តករដែលបានការអនុញ្ញាត ។

ច-ធ្វើការស៊ើបអង្កេតករណីសង្ស័យ ចំពោះអំពើល្មើសនឹងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ឬ នៃការអនុញ្ញាត ឬ អំពើល្មើសនឹងលក្ខខណ្ឌនៃច្បាប់នេះរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងចាត់វិធានការអនុវត្តសមស្របណាមួយដូចជាព្យួរ ឬ ដកហូតអាជ្ញាប័ណ្ណ ឬ ការអនុញ្ញាត ។

៩-ចាត់រាល់វិធានការសមស្របដែលច្បាប់នេះអនុញ្ញាតដើម្បីអង្កេតស្វែងរក និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ និងអំពើមិនសមស្របដែលពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ ។

**មាត្រា ៩.- សិទ្ធិអំណាចរបស់អគ្គនាយកក្នុងការគ្រប់គ្រង គ.ម.ក**

ក្នុងគោលបំណងអនុវត្តតាមមុខងារ ដែលមានចែងក្នុងច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិអំណាចដូចខាងក្រោម ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១-ផ្ដល់សិទ្ធអំណាចទៅបុគ្គលិករបស់ **គ.ម.ក.** ឬ ផ្ដល់សិទ្ធអំណាចទៅបុគ្គលផ្សេងទៀត ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន ។

២-ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** មានមូលហេតុត្រឹមត្រូវ ហើយជឿជាក់ថាបទល្មើសត្រូវបានប្រព្រឹត្តនៅក្រោមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** អាចសម្រេចឱ្យបុគ្គលិករបស់ខ្លួនធ្វើការស៊ើបអង្កេតលើ :

ក-បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណ ឬ ទទួលបានការអនុញ្ញាត ។

ខ-បុគ្គលដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ ។

គ-ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលមានមូលបត្រដាក់លក់ ឬ ដាក់តម្លៃនៅក្នុងទីផ្សារមូលបត្រ ។

ឃ-បុគ្គលផ្សេងទៀតតាមការជាក់ស្ដែង ។

៣-ប្រមូលភស្តុតាងពីបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត ។

៤-រាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការស៊ើបអង្កេតជូនប្រធាន និងសមាជិកទាំងអស់នៃ **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ដើម្បីចាត់វិធានការអនុវត្តបន្ត ។

៥-បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ពីបទល្មើស ។

៦-ធ្វើការអង្កេតលើរាល់សកម្មភាពទីផ្សារមូលបត្រប្រតិស្រុត ។

៧-ផ្សព្វផ្សាយឈ្មោះ និងសកម្មភាពរបស់បុគ្គលដែលមានពិរុទ្ធភាពពីបទល្មើសដែលមានចែងក្នុងច្បាប់នេះ ឬ ដែលទទួលទណ្ឌកម្មខាងវិន័យពី **គ.ម.ក.** ។

៨-ដកហូត ឬ ព្យួរអាជ្ញាប័ណ្ណ ការអនុញ្ញាត ឬការចុះបញ្ជីដែលបានផ្ដល់ឱ្យ ។

៩-សិទ្ធិមួយចំនួនទៀតស្របតាមមាត្រា ៤៥ នៃច្បាប់នេះ ។

**មាត្រា ១០.- សិទ្ធិពិសេសរបស់ គ.ម.ក.**

មន្ត្រីរបស់ **គ.ម.ក.** ទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានមុខងារដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្ដីពីមុខងាររបស់នគរបាលយុត្តិធម៌ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ១១.- ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក.**

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវកំណត់ដោយអនុ-ក្រឹត្យ ។ **គ.ម.ក.** ត្រូវមានថវិកាសម្រាប់ចំណាយផ្ទាល់ខ្លួនដាច់ដោយឡែក ។

## ជំពូកទី ៣

## សំណើលក់មូលបត្រ និង ការបោះផ្សាយមូលបត្រ

**មាត្រា ១២.- ការបោះផ្សាយ និងលក់មូលបត្រ**

គ្មានបុគ្គលណាមួយបោះផ្សាយ និងលក់មូលបត្រជាសាធារណៈបានទេ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពី **គ.ម.ក.** ដោយអនុលោមតាមច្បាប់និងលក្ខខណ្ឌផ្សេងៗដែលកំណត់ដោយ **គ.ម.ក.** ។ បុគ្គលនោះត្រូវបង់ថ្លៃសេវានៃការដាក់ពាក្យស្នើសុំដែលកំណត់ឡើងស្របតាមច្បាប់នេះ ។

**មាត្រា ១៣.- ការពិនិត្យលើពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវពិនិត្យរាល់ពាក្យស្នើសុំ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ និងជូនដំណឹងដល់បុគ្គលដែលបានដាក់ពាក្យស្នើសុំនោះ អំពីភាពសមស្រប ឬ មិនសមស្របនៃសំណើនោះជាមួយនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលយ៉ាងយូរ ៣(បី) ខែ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ ។

**មាត្រា ១៤.- លក្ខខណ្ឌនៃពាក្យស្នើសុំបោះផ្សាយ និងលក់មូលបត្រ**

ដើម្បីសម្រេចថា ពាក្យស្នើសុំមួយមានភាពសមស្រប ឬមិនសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា អគ្គនាយកនៃ **គ.ម.ក.** ត្រូវតែពិចារណាលើ :

១-គុណភាពនៃអភិបាលកិច្ច និងប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយមូល-បត្រ ។

២-តម្រូវការរបស់ទីផ្សារមូលបត្រ រួមទាំងតម្រូវការដើម្បីអភិវឌ្ឍទីផ្សារមូលបត្រ ។

៣-កត្តាជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រជាសាធារណៈ រួមទាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

អត្ថិភាពនៃកិច្ចសន្យាធានាទិញ ឬគម្រោងចុះកិច្ចសន្យាធានាទិញដែលនឹងធានាថា រាល់មូល-បត្រទាំងអស់ដែលប្រកាសលក់ក្នុងក្របខ័ណ្ឌនៃសំណើលក់ជាសាធារណៈនោះ អាចបោះផ្សាយបាន ឬ អាចលក់អស់ ។

៤-លក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីដើម្បីលក់នៅទីផ្សារមូលបត្រ ។

៥-លក្ខខណ្ឌផ្សេងៗ តម្រូវក្នុងការផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានឱ្យស្របតាមជំពូកនេះ ។

៦-បញ្ហាផ្សេងៗទៀត ដែលអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថាមានលក្ខណៈសមស្របក្នុងការការពារផលប្រយោជន៍សាធារណៈ ។

## មាត្រា ១៥.– ការយល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ

ប្រសិនបើ **គ.ម.ក.** យល់ព្រមលើសំណើបោះផ្សាយ និងលក់មូលបត្រ ដែលដាក់ជូនតាមមាត្រា ១២ នៃច្បាប់នេះ បុគ្គលដែលធ្វើសំណើនោះអាចចាប់ផ្តើមធ្វើសំណើបោះផ្សាយ និងលក់មូលបត្រជាសាធារណៈ ដោយអនុលោមតាមច្បាប់នេះ ។

## មាត្រា ១៦.– ការដាក់លក់មូលបត្រជាសាធារណៈ

គ្មានបុគ្គលណាមួយធ្វើសំណើលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ លើកលែងតែសំណើលក់នោះ ធ្វើឡើងដោយគោរពតាមលក្ខខណ្ឌខាងក្រោម៖

១-មូលបត្រដែលធ្វើសំណើលក់នោះ ត្រូវបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដោយនីតិបុគ្គលប្រតិស្រុត ដែលត្រូវបានកំណត់ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

២-រាល់លក្ខខណ្ឌនៃការស្នើសុំលក់ និងឯកសារផ្តល់ព័ត៌មានដែលត្រូវបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌដទៃទៀតដែលត្រូវបានកំណត់ស្របតាមច្បាប់នេះ ត្រូវតែទទួលបានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** លើកលែងតែការដាក់លក់នោះ គឺជាការដាក់លក់មូលបត្រអញ្ញត្រកម្មដូចមានចែងក្នុងអនុក្រឹត្យ ដោយអនុលោមតាមច្បាប់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

នេះ ។ ចំពោះឯកសារផ្តល់ព័ត៌មានត្រូវតែចុះបញ្ជីនៅ **គ.ម.ក.** ។

**មាត្រា ១៧.– បែបបទនៃការដាក់លក់មូលបត្រ និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន**

បុគ្គលណាដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈ ត្រូវដាក់ពាក្យសុំការអនុញ្ញាតធ្វើសំណើលក់នោះ និងសុំការអនុញ្ញាតចុះបញ្ជីឯកសារផ្តល់ព័ត៌មានដែលទាក់ទងទៅនឹងសំណើលក់ទៅ **គ.ម.ក.** ។ បុគ្គលស្នើសុំត្រូវ :

១-ដាក់ពាក្យសុំមួយច្បាប់តាមទម្រង់កំណត់ដែលរួមមានលក្ខខណ្ឌនៃសំណើលក់ជាសាធារណៈនៃមូលបត្រ និងឯកសារផ្តល់ព័ត៌មានមួយច្បាប់ ដែលបំពេញតាមលក្ខខណ្ឌរបស់ច្បាប់នេះព្រមទាំងលក្ខខណ្ឌទាំងឡាយណា ដែលត្រូវបានកំណត់ដោយអនុលោមតាមច្បាប់នេះ ។

២-បង់ថ្លៃសេវាតាមការកំណត់សម្រាប់ការដាក់ពាក្យស្នើសុំ ។

**មាត្រា ១៨.– ការចុះបញ្ជី និងការយល់ព្រមលើឯកសារផ្តល់ព័ត៌មាន**

អគ្គនាយកនៃ **គ.ម.ក.** អាចផ្តល់ការអនុញ្ញាត ចំពោះឯកសារផ្តល់ព័ត៌មាន និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានដែលបានដាក់ជូន **គ.ម.ក.** ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថាឯកសារនោះបំពេញតាមលក្ខខណ្ឌរបស់ច្បាប់ និងលក្ខខណ្ឌផ្សេងៗដែលត្រូវបានកំណត់អនុលោមតាមច្បាប់នេះ ។

**មាត្រា ១៩.– ការបដិសេធលើឯកសារផ្តល់ព័ត៌មាន**

ការសម្រេចបដិសេធចំពោះការផ្តល់ការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានត្រូវធ្វើឡើងដូចខាងក្រោម :

១-ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ឯកសារផ្តល់ព័ត៌មានដែលបានដាក់សុំការអនុញ្ញាតនោះ ពុំបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ និងលក្ខខណ្ឌផ្សេងៗដទៃទៀតដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យស្នើសុំដោយផ្តល់នូវ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ក-មូលហេតុ ។

ខ-ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំ ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដើម្បីធ្វើការពន្យល់បន្ថែមលើគុណសម្បត្តិនៃសំណើដាក់លក់មូលបត្រជាសាធារណៈនោះ ។

គ-ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំ ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រដើម្បីធ្វើការកែប្រែឯកសារផ្ដល់ព័ត៌មាន ។

២-ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** នៅតែពិនិត្យឃើញថាឯកសារផ្ដល់ព័ត៌មានដែលតម្រូវឱ្យកែប្រែនោះ នៅតែមិនបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងលក្ខខណ្ឌផ្សេងៗដទៃទៀតដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យស្នើសុំយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបានថាឯកសារផ្ដល់ព័ត៌មានត្រូវបានបដិសេធមិនឱ្យចុះបញ្ជី ។

**មាត្រា ២០.- ឯកសារផ្ដល់ព័ត៌មានបន្ថែម**

ក្នុងរយៈពេលឯកសារផ្ដល់ព័ត៌មាននៅមានសុពលភាព បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវដាក់ឯកសារផ្ដល់ព័ត៌មានបន្ថែម ឬ ឯកសារផ្ដល់ព័ត៌មានជំនួសជូនទៅ**គ.ម.ក.** ដើម្បីសុំការអនុញ្ញាត និងចុះបញ្ជី ប្រសិនបើឯកសារផ្ដល់ព័ត៌មានមាន :

១-ការកែប្រែ ឬ ផ្លាស់ប្ដូរព័ត៌មាន ដែលប៉ះពាល់ដល់ខ្លឹមសារឯកសារផ្ដល់ព័ត៌-មានដែលបានផ្ដល់ ។

២-បញ្ហាសំខាន់ថ្មីបានកើតឡើងដោយសារតែច្បាប់ ឬ លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយអនុលោមតាមច្បាប់នេះ បានតម្រូវឱ្យបង្ហាញបញ្ហាសំខាន់ថ្មីនោះ ទោះបីជាឯក-សារផ្ដល់ព័ត៌មានត្រូវបានរៀបចំហើយក៏ដោយ ។

៣-ឯកសារផ្ដល់ព័ត៌មាន ដែលបានផ្ដល់មានបង្កប់នូវព័ត៌មានសំខាន់ណាមួយដែលមានលក្ខណៈមិនច្បាស់លាស់ ឬ ក្លែងបន្លំ ឬ ដែលនាំឱ្យយល់ខុស ឬ មានការខកខានមិនបានបង្ហាញនូវចំណុចសំខាន់ដែលត្រូវដាក់ក្នុងឯកសារផ្ដល់ព័ត៌មាន ។

បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រ មិនត្រូវផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសជាសាធារណៈ លើកលែងតែឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសនោះ ទទួលបានការអនុញ្ញាត និងចុះបញ្ជីពី **គ.ម.ក.** ។

## មាត្រា ២១.- ការព្យួរ ឬ ការលុបចោលឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួច

អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិព្យួរការចុះបញ្ជីនៃឯកសារផ្តល់ព័ត៌មាន ដើម្បីការពារផលប្រយោជន៍សាធារណៈ ក្នុងករណីអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចហើយ ដោយរួមទាំងឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសនោះ :

១-មានព័ត៌មានដែលមានលក្ខណៈក្លែងបន្លំ ឬ ដែលនាំឱ្យយល់ខុស ឬ ខកខានពុំបានផ្តល់ព័ត៌មានសំខាន់ណាមួយ ។

២-ពុំបានអនុវត្តតាមច្បាប់ ឬ លក្ខខណ្ឌផ្សេងទៀត ដែលបានកំណត់អនុលោមតាមច្បាប់នេះ ។

ការព្យួរការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ត្រូវធ្វើឡើងក្នុងរយៈពេលជាក់លាក់ណាមួយ មិនឱ្យលើសពី ០១ (មួយ) ខែ ហើយបន្ទាប់ពីផុតរយៈពេលនៃការព្យួរនេះ បើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា បញ្ហាដែលបណ្តាលឱ្យមានការព្យួរមិនត្រូវបានដោះស្រាយឱ្យបានសមស្រប អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិលុបចោលការចុះបញ្ជីឯកសារផ្តល់ព័ត៌មាននោះ ។

## មាត្រា ២២.- លក្ខខណ្ឌបន្ថែមទាក់ទងនឹងសំណើលក់ និងការបោះផ្សាយមូលបត្រ

លក្ខខណ្ឌបន្ថែមទៀតដែលទាក់ទងនឹងការគ្រប់គ្រង និងត្រួតពិនិត្យសំណើលក់ជាសាធារណៈ និងការបោះផ្សាយមូលបត្រ ត្រូវកំណត់ដោយ **គ.ម.ក.** ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង



15/43

# ជំពូកទី ៤

# ដំណើរការរបស់ទីផ្សារមូលបត្រ

## មាត្រា ២៣.- ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ

គ្មានបុគ្គលណាមួយ អាចធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រឡើយ លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមច្បាប់នេះ ឬ ច្បាប់ផ្សេងៗទៀតជាធរមាន ។ មាត្រានេះមិនត្រូវបានអនុវត្តចំពោះធនាគារជាតិនៃកម្ពុជាទេ ដែលអាចធ្វើប្រតិបត្តិការប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ។

## មាត្រា ២៤.- ការដាក់ពាក្យស្នើសុំធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ

ការដាក់ពាក្យស្នើសុំ ដើម្បីធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ត្រូវធ្វើឡើងដូចខាងក្រោម :

១-បុគ្គល ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពី **គ.ម.ក.** ដើម្បីធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ តាមទម្រង់ដែលបានកំណត់ និងបង់ថ្លៃសេវាតាមការកំណត់របស់ **គ.ម.ក.** ។

២-ក្រោយពីទទួលបានពាក្យស្នើសុំតាមកថាខណ្ឌ (១) អគ្គនាយកនៃ **គ.ម.ក.** ត្រូវបញ្ជូនពាក្យស្នើសុំមួយច្បាប់ជូនប្រធាន **គ.ម.ក.** និងសមាជិកនៃ **គ.ម.ក.** ទាំងអស់ ដើម្បីផ្តល់អនុសាសន៍លើពាក្យស្នើសុំនោះឱ្យ បានយ៉ាងឆាប់តាមការជាក់ស្តែង ។

៣-អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែម តាមការចាំបាច់ ។ ក្នុងករណីអ្នកដាក់ពាក្យស្នើសុំមិនបានផ្តល់ព័ត៌មានបន្ថែម អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធមិនពិនិត្យពាក្យស្នើសុំនោះ ។



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
16/45

## មាត្រា ២៥.- ការអនុញ្ញាតលើពាក្យស្នើសុំ

ការសម្រេចផ្តល់ការអនុញ្ញាតលើការស្នើសុំធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រមានដូចតទៅ :

១-ក្រោយពីទទួលបានការសម្រេចពីការប្រជុំពេញអង្គរបស់ **គ.ម.ក.** មក អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ការអនុញ្ញាតដល់បុគ្គល ដើម្បីដាក់ឱ្យធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ ។

២-អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការពន្យល់ ។

៣-ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ផ្តល់ការអនុញ្ញាតតាមកថាខណ្ឌ (១) :

-ការអនុញ្ញាតត្រូវធ្វើឡើង ដោយគោរពតាមលក្ខខណ្ឌកំណត់ អនុលោមតាមច្បាប់នេះ

-ក្នុងរយៈពេលដែលការអនុញ្ញាតនៅមានសុពលភាព អគ្គនាយកនៃ **គ.ម.ក.** អាចកំណត់នូវលក្ខខណ្ឌបន្ថែម ឬ កែប្រែ ឬ ដកហូតលក្ខខណ្ឌបន្ថែមណាមួយមកវិញបាន ក្រោយពីបានទទួលការសម្រេចរបស់ **គ.ម.ក** ។

## មាត្រា ២៦.- លក្ខខណ្ឌតម្រូវឱ្យមានប្រព័ន្ធផាត់ទាត់ និងទូទាត់

មុនពេលដែលអគ្គនាយកនៃ **គ.ម.ក.** ផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដើម្បីដាក់ឱ្យដំណើរការប្រតិបត្តិការទីផ្សារមូលបត្រ អ្នកដាក់ពាក្យស្នើសុំត្រូវបញ្ជាក់ជូន **គ.ម.ក.** អំពីលទ្ធភាពរបស់ខ្លួនក្នុងការរៀបចំឱ្យមានការប្រើប្រាស់ប្រព័ន្ធផាត់ទាត់និងទូទាត់មួយសមស្របសម្រាប់ប្រតិបត្តិការជួញដូរនៅក្នុងទីផ្សារមូលបត្រនោះ ។

**មាត្រា ២៧.- ការព្យួរ និងការដកហូត ការអនុញ្ញាត**

សិទ្ធិអំណាចរបស់អគ្គនាយកនៃ **គ.ម.ក.** ក្នុងការគ្រប់គ្រងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ មានដូចតទៅ :

១-ក្រោយពេលផ្តល់ការអនុញ្ញាតស្របតាមជំពូកនេះ ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់និងប្រតិបត្តិកររក្សាទុកមូលបត្របានបំពានលើលក្ខខណ្ឌនៃការអនុញ្ញាត ឬ លក្ខខណ្ឌរបស់ច្បាប់ និងលក្ខខណ្ឌផ្សេងទៀតដែលបានកំណត់តាមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិចាត់វិធានការដូចខាងក្រោម :

ក-ដឹកនាំកែតម្រង់បុគ្គលដែលទទួលបានការអនុញ្ញាតឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវ ។

ខ-ដាក់លក្ខខណ្ឌ ឬ កំហិតបន្ថែមលើការអនុញ្ញាត ។

គ-ព្យួរការអនុញ្ញាត រហូតដល់អ្នកដែលទទួលបានការអនុញ្ញាតនោះអនុវត្តតាមលក្ខខណ្ឌតម្រូវឱ្យបានពេញលេញ ។

ឃ-ដកហូតការអនុញ្ញាតនោះមកវិញ ។

២-អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវចាត់វិធានការស្របតាមកថាខណ្ឌ(១) ដោយមិនបានសុំយោបល់ **គ.ម.ក.** ដោយបើកធ្វើការប្រជុំពេញអង្គជាមុន និង ដោយមិនបានផ្តល់ដល់អ្នកទទួលបានការអនុញ្ញាតនូវមូលហេតុជាលាយលក្ខណ៍អក្សរ និងមិនផ្តល់ឱកាសឱ្យអ្នកទទួលបានការអនុញ្ញាតធ្វើការពន្យល់ ។

**មាត្រា ២៨.- វិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រដែលមានការអនុញ្ញាត**

គ្មានបុគ្គលណា អាចដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬ សេវារក្សាទុកមូលបត្រ លើកលែងតែទទួលបានការ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង



18/43

អនុញ្ញាតពី **គ.ម.ក.** ។ វិធានប្រតិបត្តិការ និងនីតិវិធីនោះ ត្រូវចែងអំពីបញ្ញត្តិនានា ដែលទាក់ទងនឹងការគ្រប់គ្រងឱ្យបានច្បាស់លាស់ហើយឱ្យស្របតាមច្បាប់នេះ ។

### មាត្រា ២៩.- លក្ខខណ្ឌបន្ថែមដែលមានទាក់ទងនឹងការប្រព្រឹត្តទៅរបស់ទីផ្សារបន្ទាប់

ការលក់ ឬ ការទិញមូលបត្រដែលបោះផ្សាយលក់ អនុលោមតាមច្បាប់នេះ ត្រូវបានគ្រប់គ្រងដោយលក្ខខណ្ឌបន្ថែមដែលកំណត់ដោយ **គ.ម.ក.** ។

### មាត្រា ៣០.- ការគោរពលក្ខខណ្ឌ និងលក្ខខណ្ឌបន្ថែមនៃការអនុញ្ញាត

បុគ្គលដែលបានទទួលការណែនាំពីអគ្គនាយកនៃ **គ.ម.ក.** តាមមាត្រា ២៧(១) នៃច្បាប់នេះ ឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនៃការអនុញ្ញាត ត្រូវតែគោរពតាមការណែនាំក្នុងរយៈពេលជាក់លាក់មួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ។

## ជំពូកទី ៥

## អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ

### មាត្រា ៣១.- ការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ

គ្មានបុគ្គលណាមួយអាចធ្វើអាជីវកម្មមូលបត្រ ឬ តាំងខ្លួនជាអ្នកធ្វើអាជីវកម្មមូលបត្រក្នុងទម្រង់ជាក្រុមហ៊ុនមូលបត្របានទេ លើកលែងតែបុគ្គលនោះទទួលអាជ្ញាប័ណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ឬពាណិជ្ជករមូលបត្រអញ្ញត្រកម្ម ឬ ពាណិជ្ជករពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រអញ្ញត្រកម្មដែលកំណត់ដោយអនុក្រឹត្យ ។

គ្មានជនណាមួយអាចធ្វើជាភ្នាក់ងារ ឬ តាំងខ្លួនជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រប្រតិស្រុតដើម្បីធ្វើអាជីវកម្មមូលបត្របានទេ លុះត្រាតែជននោះត្រូវបានផ្តល់អាជ្ញាប័ណ្ណដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រអនុលោមតាមច្បាប់នេះ ។

### មាត្រា ៣២.- ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ត្រូវធ្វើដូចតទៅ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



19/43

១-បុគ្គលមួយអាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬ ធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រទៅអគ្គនាយកនៃ **គ.ម.ក.** តាមទម្រង់បែបបទដែលបានកំណត់ និងដោយបង់ថ្លៃសេវាតាមការកំណត់របស់ **គ.ម.ក.** ។

២-អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចបដិសេធមិនពិនិត្យពាក្យស្នើសុំនោះ រហូតដល់អ្នកដាក់ពាក្យស្នើសុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់ ។

**មាត្រា ៣៣.- ការពិនិត្យ និងសម្រេចលើពាក្យស្នើសុំអាជ្ញាប័ណ្ណ**

ការសម្រេចផ្តល់អាជ្ញាប័ណ្ណ និងលក្ខខណ្ឌអាជ្ញាប័ណ្ណ ត្រូវអនុវត្តដូចខាងក្រោម :

១-អគ្គនាយកនៃ **គ.ម.ក.** អាចផ្តល់អាជ្ញាប័ណ្ណដល់អ្នកដាក់ពាក្យស្នើសុំ ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬ ធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌ ដែលបានកំណត់ដោយ **គ.ម.ក.** ។ នៅក្នុងរយៈពេលដែលអាជ្ញា-ប័ណ្ណនៅមានសុពលភាព ប្រសិនបើលក្ខខណ្ឌដែលបានកំណត់ដោយ **គ.ម.ក.** មានការប្រែប្រួល អ្នកដាក់ពាក្យស្នើសុំដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវបន្តបំពេញតាមលក្ខខណ្ឌប្រែប្រួលនោះ ។

២-អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវបដិសេធក្នុងការផ្តល់អាជ្ញាប័ណ្ណជូនអ្នកដាក់ពាក្យស្នើសុំ ដោយមិនបញ្ជាក់ពីមូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងដោយមិនបានផ្តល់ឱកាសដល់អ្នកដាក់ពាក្យស្នើសុំឱ្យធ្វើការពន្យល់ឡើយ ។

៣-ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ផ្តល់អាជ្ញាប័ណ្ណតាមកថាខណ្ឌ (១) :

-អាជ្ញាប័ណ្ណដែលផ្តល់នោះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិ និងលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក**

-អាជ្ញាប័ណ្ណដែលផ្តល់នោះ ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌ ឬ ការដាក់កំហិតណាមួយតាមការចាំបាច់ រួមទាំងលក្ខខណ្ឌដែលដាក់កំហិតលើប្រភេទអាជីវកម្មណាមួយដែលមានក្នុងអាជ្ញាប័ណ្ណ និង

-ក្នុងរយៈពេលដែលអាជ្ញាប័ណ្ណនៅមានសុពលភាព អគ្គនាយកនៃ **គ.ម.ក.** អាចកំណត់នូវលក្ខខណ្ឌបន្ថែមលើអាជ្ញាប័ណ្ណ កែប្រែ ឬ ដកលក្ខខណ្ឌណាមួយមកវិញ ក្រោយទទួលបានការសម្រេចរបស់**គ.ម.ក.** ។

**មាត្រា ៣៤.- ការព្យួរ និងការដកហូតអាជ្ញាប័ណ្ណ**

វិធានការចំពោះអ្នកកាន់អាជ្ញាប័ណ្ណមានដូចតទៅ :

១-ក្រោយពេលផ្តល់អាជ្ញាប័ណ្ណក្រោមជំពូកនេះ ប្រសិនបើអគ្គនាយកនៃ**គ.ម.ក.** ពិនិត្យឃើញថា អ្នកកាន់អាជ្ញាប័ណ្ណបានបំពានលើលក្ខខណ្ឌណាមួយនៃអាជ្ញាប័ណ្ណ ឬ លក្ខខណ្ឌណាមួយដែលកំណត់ដោយ**គ.ម.ក.** ឬ បទប្បញ្ញត្តិណាមួយដែលបានកំណត់ដោយអនុលោមតាមច្បាប់នេះ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការដូចខាងក្រោម :

-ដឹកនាំកែតម្រង់អ្នកកាន់អាជ្ញាប័ណ្ណឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនោះ

-ដាក់កំហិតលើអាជ្ញាប័ណ្ណ

-ព្យួរអាជ្ញាប័ណ្ណនោះ រហូតដល់អ្នកកាន់អាជ្ញាប័ណ្ណបានគោរពតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមពេញលេញ

-ដកហូតអាជ្ញាប័ណ្ណមកវិញ ។

២-អគ្គនាយកនៃ **គ.ម.ក.** មិនត្រូវចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌ (១) ដោយមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ដល់អ្នកកាន់អាជ្ញាប័ណ្ណអំពីមូលហេតុនៃការចាត់វិធានការនេះ និងដោយមិនផ្តល់ឱកាសឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើការពន្យល់ឡើយ ។

**មាត្រា ៣៥.- លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ និងការផ្តល់អាជ្ញាប័ណ្ណដល់ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ និងអ្នកចូលរួមដទៃទៀត**

លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ និងការផ្តល់អាជ្ញាប័ណ្ណដល់ទីប្រឹក្សាវិនិយោគ ពាណិជ្ជករ មូលបត្រនិងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ ឬ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុក

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មូលបត្រត្រូវកំណត់ដោយ **គ.ម.ក.** ។

## មាត្រា ៣៦.- ការបង្កើត និងការរក្សាបញ្ជីអាជ្ញាប័ណ្ណ

អគ្គនាយកនៃ **គ.ម.ក.** ត្រូវបង្កើត និងរក្សាបញ្ជីអាជ្ញាប័ណ្ណទាំងអស់ដែលខ្លួនបានផ្តល់ តាមទម្រង់បែបបទត្រឹមត្រូវ ដោយចុះបញ្ជាក់នូវព័ត៌មានជាក់លាក់មួយចំនួន ។

## មាត្រា ៣៧.- ការគោរពលក្ខខណ្ឌ និងលក្ខខណ្ឌបន្ថែមនៃអាជ្ញាប័ណ្ណ

បុគ្គលណាដែលបានទទួលការណែនាំពីអគ្គនាយកនៃ **គ.ម.ក.** តាមមាត្រា ៣៤(១) នៃ ច្បាប់នេះឱ្យអនុវត្តតាមលក្ខខណ្ឌ ឬ លក្ខខណ្ឌបន្ថែមនៃអាជ្ញាប័ណ្ណ ត្រូវតែគោរពតាមការ ណែនាំក្នុងរយៈពេលជាក់លាក់មួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ។

# ជំពូកទី ៦

# អភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

## មាត្រា ៣៨.- លក្ខខណ្ឌនៃអភិបាលកិច្ច ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដទៃទៀត

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដទៃទៀត ដែល បោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឱ្យ បាន ម៉ឺងម៉ាត់នូវបទប្បញ្ញត្តិនានាជាធរមាន និងរាល់លក្ខខណ្ឌទាំងឡាយស្តីពីអភិបាលកិច្ច ដែល កំណត់ដោយ **គ.ម.ក.** ដើម្បីការពារផលប្រយោជន៍ដល់ការប្រព្រឹត្តទៅនៃទីផ្សារមូលបត្រនិង ដើម្បីការពារផលប្រយោជន៍អ្នកវិនិយោគសាធារណៈ ។

## មាត្រា ៣៩.- លក្ខខណ្ឌគ្រប់គ្រងសាជីវកម្ម

លក្ខខណ្ឌគ្រប់គ្រងសាជីវកម្មអាចត្រូវកំណត់ដោយ **គ.ម.ក.** ដើម្បីគ្រប់គ្រងលើ :

- បែបបទក្នុងការទទួលបានសិទ្ធិកាន់កាប់លើភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដទៃទៀត ដែលបោះផ្សាយលក់ជាសាធារណៈនូវភាគហ៊ុនមានសិទ្ធិបោះឆ្នោត ។ លក្ខខណ្ឌដែលត្រូវបានកំណត់នោះមានគោលបំណងដើម្បីធានាថាការទទួលបានសិទ្ធិគ្រប់គ្រងលើភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលនោះ ធ្វើឡើងប្រកបដោយយុត្តិធម៌ និងតម្លាភាព ។

-ការផ្តល់ព័ត៌មានអំពីកម្មសិទ្ធិនៃការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើននៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់ជាសាធារណៈនូវភាគហ៊ុនមានសិទ្ធិបោះឆ្នោត ។ លក្ខខណ្ឌដែលត្រូវបានកំណត់នោះមានគោលបំណងដើម្បីធានាថា អ្នកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត អាចដឹងពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ភាគហ៊ុនចំនួនច្រើននៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលនោះ ។

## ជំពូកទី ៧

## អាកប្បកិរិយាដែលត្រូវបានហាមឃាត់ទាក់ទិនទៅនឹងមូលបត្រ

### មាត្រា ៤០.- ការជួញដូរផ្ទៃក្នុង

អ្នកផ្ទៃក្នុងត្រូវបានកំណត់ដូចខាងក្រោម :

-អគ្គនាយក នាយក គណៈគ្រប់គ្រង និងបុគ្គលិករបស់ក្រុមហ៊ុន ឬ របស់នីតិ-បុគ្គលប្រតិស្រុត និងភាគហ៊ុនិកនៅក្នុងក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតដែលកាន់កាប់យ៉ាងតិច ៥ (ប្រាំ) ភាគរយនៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត និងបុគ្គលដទៃទៀត ដែលទំនាក់ទំនងរបស់បុគ្គលនោះជាមួយនឹងក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតផ្តល់ឱ្យខ្លួនមាន ឬ ទទួលបាននូវព័ត៌មានសម្ងាត់ទាក់ទិននឹងសកម្មភាពរបស់ក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុត

-ប្រធាន សមាជិក អគ្គនាយក នាយក និងបុគ្គលិករបស់ **គ.ម.ក.** ទាំងអស់ និងមន្ត្រីពាក់ព័ន្ធដទៃទៀតរបស់រាជរដ្ឋាភិបាល ឬ បុគ្គលិករបស់នីតិបុគ្គលដែលទទួលបានការអនុញ្ញាត ឬ ទទួលបានអាជ្ញាប័ណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ឱ្យធ្វើជាអន្តរការីនៅក្នុងទីផ្សារ

មូលបត្រដែលមាន ឬ ទទួលបានទូវព័ត៌មានសម្ងាត់ទាក់ទិននឹងសកម្មភាពរបស់ក្រុមហ៊ុន ឬ នីតិបុគ្គលប្រតិស្រុតដោយសារតែតួនាទីរបស់ខ្លួន ។

ព័ត៌មានផ្ទៃក្នុងសំដៅដល់ព័ត៌មានទាំងឡាយណាទាក់ទិននឹងមូលបត្រដែលត្រូវបោះផ្សាយ និង បានបោះផ្សាយ ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ហើយព័ត៌មានទាំងនោះមិនទាន់ផ្សព្វផ្សាយជាទូទៅ ប៉ុន្តែប្រសិនបើព័ត៌មានទាំងនោះនឹងដល់សាធារណជន អាចមានផលប៉ះពាល់ខ្លាំងដល់តម្លៃ ឬ ទិន្នភាពជួញដូរដទៃទៀតរបស់មូលបត្រទាំងនោះ ។

អ្នកផ្ទៃក្នុងដូចមានចែងក្នុងកថាខណ្ឌទី ១ មិនត្រូវ :

-ឆ្លៀតប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដែលចែងក្នុងកថាខ័ណ្ឌទី ២ ខាងលើ ដោយផ្ទាល់ ឬ មិនផ្ទាល់ ដើម្បីជួញដូរមូលបត្ររបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតក្នុងគោលបំណងរកចំណេញ ឬ បញ្ចៀសការខាតបង់ផ្ទាល់ខ្លួន

-ផ្តល់ព័ត៌មានផ្ទៃក្នុងដល់បុគ្គលដទៃណាមួយ ឬ នីតិបុគ្គលប្រតិស្រុតណាមួយក្នុងគោលបំណងធ្វើឱ្យបុគ្គលនោះ ឬ នីតិបុគ្គលប្រតិស្រុតនោះរកចំណេញឬ បញ្ចៀសការខាតបង់ ។

## មាត្រា ៤១.- ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ

នោះបីជាដោយចេតនា ឬ ដោយធ្វេសប្រហែសក្តី បុគ្គលមិនត្រូវ :

១-ធ្វើសកម្មភាពណាមួយ ឬ គេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឱ្យ ឬ អាចបណ្តាលឱ្យមានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុសចំពោះការជួញដូរមូលបត្រដែលគេកំពុងជួញដូរនៅលើទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា ។ ឬ

២-ធ្វើប្រតិបត្តិការ ឬ ធ្វើផែនការជួញដូរ ដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រ ហើយប្រសិនបើប្រតិបត្តិការនោះបណ្តាលឱ្យ :

-តម្លៃនៃការជួញដូរមូលបត្រ នៅលើទីផ្សារមូលបត្រ នៅក្នុងប្រទេសកម្ពុជានៅថេរ កើនឡើង ឬ ស្រុតចុះ និង

-មានចលនាឡើង ចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងប្រទេសកម្ពុជា ។

**មាត្រា ៤២.- សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស**

បុគ្គលមិនត្រូវធ្វើសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានប្រសិនបើ :

១-សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះមានលក្ខណៈក្លែងបន្លំ ឬ មានលក្ខណៈនាំឱ្យយល់ខុសធ្ងន់ធ្ងរ ។

២-សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានទាំងនោះអាច :

-បណ្តាលឱ្យសាធារណជននៅក្នុងប្រទេសកម្ពុជា ទិញ ឬ លក់មូលបត្រ ឬ

-បណ្តាលឱ្យមានការកើនឡើង ការថយចុះ ឬ ការនៅថេរចំពោះតម្លៃនៃការជួញដូរមូលបត្រដែលជួញដូរនៅលើទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជា ។

៣-នៅពេលដែលបុគ្គលនោះធ្វើសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាន :

-បុគ្គលនោះមិនគិតថា សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះពិត ឬ ក្លែងបន្លំ ឬ

-បុគ្គលនោះដឹង ឬ គួរដឹងថាសេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មាននោះគឺក្លែងបន្លំ និងមានលក្ខណៈធ្វើឱ្យយល់ខុស ។

## ជំពូកទី ៨

## ការដោះស្រាយវិវាទ និង វិធានការពិន័យរដ្ឋបាល

**មាត្រា ៤៣.- ការផ្សះផ្សាវិវាទ**

គ្រប់វិវាទដែលពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មមូលបត្រ ភាគីជម្លោះអាចនាំយកវិវាទនោះជូនទៅ គ.ម.ក. ដើម្បីធ្វើការផ្សះផ្សាមុននឹងប្តឹងទៅតុលាការ លើកលែងតែរឿងព្រហ្មទណ្ឌ ។

**មាត្រា ៤៤.- នីតិវិធីនៃការផ្សះផ្សាវិវាទ និងដោះស្រាយវិវាទ**

**គ.ម.ក.** ក្រោយពីបានទទួលពាក្យប្តឹងហើយ ត្រូវសាកសួរភាគីទាំងសងខាងឱ្យដឹងពីកម្មវត្ថុនៃវិវាទ រួចសាកល្បងផ្សះផ្សាភាគីដោយយកច្បាប់ វិធាន និងបទប្បញ្ញត្តិផ្សេងៗជាមូលដ្ឋាន ។

លទ្ធផលផ្សះផ្សា ត្រូវមានចុះក្នុងកំណត់ហេតុធ្វើដោយ **គ.ម.ក.** បញ្ជាក់ការយល់ព្រម ឬមិនយល់ព្រមផ្សះផ្សានៃភាគី ។ កំណត់ហេតុត្រូវមានចុះហត្ថលេខាដោយ **គ.ម.ក.** និងភាគីទាំងអស់ និងត្រូវចម្លងជូនគ្រប់ភាគី ។

ការព្រមព្រៀងដែលបានធ្វើឡើង នៅចំពោះមុខ **គ.ម.ក.** គឺជាការព្រមព្រៀងដែលមានអានុភាពអនុវត្ត ។

ក្នុងករណីដែលគ្មានការសះជានឹងគ្នា សាមីភាគីអាចស្នើសុំឱ្យបញ្ជូនកំណត់ហេតុមិនសះជាទៅវេទិកាមជ្ឈត្តកម្មមានសមត្ថកិច្ច ឬ ប្តឹងទៅតុលាការមានសមត្ថកិច្ច ។ អាជ្ញាយុកាលនៃបណ្តឹងទៅវេទិកាមជ្ឈត្តកម្មមានសមត្ថកិច្ច ឬ ប្តឹងទៅតុលាការមានសមត្ថកិច្ច មានរយៈពេល ៩០(កៅសិប) ថ្ងៃ ពុំនោះទេ សិទ្ធិប្តឹងនេះនឹងត្រូវបាត់បង់ ។

**មាត្រា ៤៥.- វិធានការបន្ថែមរបស់ គ.ម.ក.**

ដើម្បីបន្ថែមទៅលើវិធានការដែល **គ.ម.ក.** ដាក់ឱ្យអនុវត្តនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ **គ.ម.ក.** អាចចាត់វិធានការដូចខាងក្រោម :

១- ក្នុងករណីដែលមានការប្រព្រឹត្តល្មើសនឹងច្បាប់ ឬ បទប្បញ្ញត្តិ ដែលធ្វើឡើងអនុលោមតាមច្បាប់នេះ ឬ រំលោភលើច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត អគ្គនាយកនៃ **គ.ម.ក.** អាច :

-ចេញលិខិតព្រមានទៅបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់នេះ ឬ ច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត

-ចេញបទបញ្ជាឱ្យបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

នេះ ឬ ច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត ធ្វើការជួសជុលសំណងល្មើសនកម្ម ស្របតាមច្បាប់នេះ និងច្បាប់ដទៃទៀត ទៅតាមអំពើល្មើសដែលបុគ្គលនោះ បានប្រព្រឹត្តនៅកាលបរិច្ឆេទជាក់លាក់មួយ

-ស្នើសុំទៅតុលាការមានសមត្ថកិច្ច ដើម្បីចេញដីកាតម្រូវឱ្យបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀតឱ្យអនុវត្តតាមច្បាប់ និងឱ្យជួសជុលសំណងល្មើសនកម្មតាមការកំណត់របស់តុលាការដែលមានអំណាចឆន្ទានុសិទ្ធិសម្រេច

-ចាត់វិធានការផាកពិន័យអន្តរការណ៍ ឬ ដាក់ទណ្ឌកម្មរដ្ឋបាលលើបុគ្គលដែលពិនិត្យឃើញថា បានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌនៃច្បាប់ ។ ការដាក់ទណ្ឌកម្មរដ្ឋបាលត្រូវកំណត់ដោយ **គ.ម.ក.**

-ព្យួរជាបណ្ដោះអាសន្ន ឬ បញ្ឈប់ការងាររបស់អគ្គនាយក នាយក សមាជិកគណៈគ្រប់គ្រង ឬ បុគ្គលិកជាន់ខ្ពស់របស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត

-ជ្រើសរើស និងផ្ដល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬ សកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត ។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ទៅឱ្យអគ្គនាយក **គ.ម.ក.** តាមលក្ខខណ្ឌដែលមានក្នុងកិច្ចសន្យាជាមួយអគ្គនាយកនៃ **គ.ម.ក.** និង

-ដាក់កំហិត ឬ បញ្ឈប់សកម្មភាពជាក់លាក់ ឬ ទូទៅដែលធ្វើឡើងដោយនីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត ទោះបីជាសកម្មភាពទាំងនោះ ត្រូវបានធ្វើឡើងស្រប ឬ មិនស្របតាមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ឬ នៃការអនុញ្ញាតដែលអគ្គនាយកនៃ **គ.ម.ក.** ផ្ដល់ឱ្យក៏ដោយ ។

២-ក្នុងករណីដែល **គ.ម.ក**. ពិនិត្យឃើញថា នីតិបុគ្គលមានអាជ្ញាប័ណ្ណ ឬ នីតិបុគ្គលប្រតិស្រុត អាចជាអសាធនីយ ឬ មានបញ្ហាផ្នែកហិរញ្ញវត្ថុ អគ្គនាយកនៃ **គ.ម.ក.** អាចប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីតែងតាំង ឬ ស្នើសុំទៅតុលាការ ដើម្បីតែងតាំងបុគ្គលដែល

មានសមត្ថភាពសមស្របឱ្យធ្វើជាអភិបាលបណ្ដោះអាសន្ន ដើម្បីគ្រប់គ្រង និងរៀបចំឡើងវិញ ឬ ជម្រះបញ្ជីនីតិបុគ្គលនោះ ស្របតាមច្បាប់ស្ដីពីក្ស័យធននៃព្រះរាជាណាចក្រកម្ពុជា ឬ បទប្បញ្ញត្តិផ្សេងៗទៀតដែលមានចែងក្នុងអនុក្រឹត្យ ដោយអនុលោមតាមច្បាប់នេះ ។ ក្នុងករណីដែលមានទំនាស់រវាងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនៃច្បាប់ក្ស័យធន ត្រូវយកបទប្បញ្ញត្តិនៃច្បាប់នេះមកអនុវត្ត ។

### មាត្រា ៤៦.- សិទ្ធិប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់ គ.ម.ក.

បុគ្គលដែលទទួលរងការខូចខាតដោយវិធានការ ឬ សេចក្ដីសម្រេចណាមួយរបស់ **គ.ម.ក.** អាចប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច ដើម្បីសុំឱ្យពិនិត្យឡើងវិញនូវវិធានការ ឬ សេចក្ដីសម្រេចនោះ ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

### មាត្រា ៤៧.- ការបោះផ្សាយ និងលក់មូលបត្រដោយខុសច្បាប់

បុគ្គលណាដែលបោះផ្សាយ និងលក់មូលបត្រជាសាធារណៈដោយគ្មានការអនុញ្ញាតពី **គ.ម.ក.** ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន)រៀល ដល់ ៥០០.០០០.០០០(ប្រាំរយលាន)រៀល ។

### មាត្រា ៤៨.- សំណើលក់មូលបត្រជាសាធារណៈដោយខុសច្បាប់

បុគ្គលណាដែលធ្វើសំណើលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ។

**មាត្រា ៤៩.- អំពើផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួស**

បុគ្គល ឬ ក្រុមហ៊ុនស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឬ ក្រុមហ៊ុនបោះផ្សាយមូលបត្រដែលមិនបំពេញកាតព្វកិច្ចតាមកថាខណ្ឌទី ១ នៃមាត្រា ២០ នៃច្បាប់នេះ ឬ ដែលផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានបន្ថែម ឬ ឯកសារផ្តល់ព័ត៌មានជំនួសជាសាធារណៈ ដោយគ្មានការអនុញ្ញាតពី និងចុះបញ្ជីទៅ**គ.ម.ក.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ។

**មាត្រា ៥០.- ការធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រដោយខុសច្បាប់**

បុគ្គលណាដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ដោយគ្មានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមច្បាប់នេះ ឬច្បាប់ផ្សេងៗទៀតជាធរមាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង



29/43

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ។

**មាត្រា ៥១._ វិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់ និង សេវារក្សាទុកមូលបត្រដោយខុសច្បាប់**

បុគ្គលណាដែលដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬ សេវារក្សាទុកមូលបត្រ ដោយគ្មានការអនុញ្ញាតពី **គ.ម.ក.** ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ២០០.០០០.០០០(ពីររយលាន) រៀល ។

**មាត្រា ៥២._ ការធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាប័ណ្ណ**

លើកលែងតែពាណិជ្ជករមូលបត្រអញ្ញត្រកម្ម ឬ ពាណិជ្ជករពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម បុគ្គលណាដែលធ្វើអាជីវកម្មមូលបត្រ ឬ តាំងខ្លួនជាអ្នកធ្វើអាជីវកម្មមូលបត្រក្នុងទម្រង់ជាក្រុមហ៊ុនមូលបត្រ ឬ ជនណាដែលធ្វើជា ឬ តាំងខ្លួនជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដើម្បីធ្វើអាជីវកម្មមូលបត្រ ដោយគ្មានអាជ្ញាប័ណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន) រៀល ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ។

**មាត្រា ៥៣._ ការមិនគោរពតាមការណែនាំរបស់ គ.ម.ក.**

បុគ្គលដែលមិនគោរពតាមបញ្ញត្តិនៃមាត្រា ៣០ និងមាត្រា ៣៧ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •



30/43

ក-ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះរូបវន្តបុគ្គល ។

ខ-ពី ២០.០០០.០០០(ម្ភៃលាន) រៀល ទៅ ២០០.០០០.០០០ (ពីររយលាន)រៀល ចំពោះនីតិបុគ្គល ។

## មាត្រា ៥៤.- បទល្មើសជួញដូរផ្ទៃក្នុង ជួញដូរក្លែងក្លាយ និងប្រើឧបាយកលក្នុងទីផ្សារ សេចក្តីថ្លែង ឬ ការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬ នាំឱ្យយល់ខុស

បុគ្គលដែលប្រព្រឹត្តដោយចេតនាល្មើសនឹងបញ្ញត្តិនៃមាត្រា ៤០ កថាខណ្ឌទី ៣ មាត្រា ៤១ និងមាត្រា ៤២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០(ដប់)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០(ហាសិបលាន) រៀល ដល់ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ។

## មាត្រា ៥៥.- ទោសបន្ថែមអនុវត្តចំពោះរូបវន្តបុគ្គល

ចំពោះបទល្មើសដូចមានចែងនៅក្នុងច្បាប់នេះ ទោសបន្ថែមមួយ ឬ ច្រើន ដូចខាងក្រោម អាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះ បានប្រព្រឹត្តក្នុងការប្រកបវិជ្ជាជីវៈ ឬក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ។

២-ការហាមឃាត់ ការបើកបរយានយន្តគ្រប់ប្រភេទ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

៣-ការហាមឃាត់នូវការស្នាក់អាស្រ័យនៅ សម្រាប់រយៈពេលមិនលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទល្មើសឧក្រិដ្ឋ និងសម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ) ឆ្នាំ ចំពោះបទល្មើសមជ្ឈិម ។

៤-ការហាមឃាត់ទណ្ឌិតបរទេសនូវការចូលមក និងស្នាក់អាស្រ័យនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ) ឆ្នាំ ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាគោលដៅនៃបទល្មើស ។

៧-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសនូវឧបភោគភណ្ឌ សម្ភារៈ និងគ្រឿងសង្ហារឹមតែងលម្អទីតាំងដែលក្នុងទីតាំងនោះបទល្មើសត្រូវបានប្រព្រឹត្ត ។

៩-ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១០-ការបិទគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់សម្រាប់ត្រៀមរៀបចំបទល្មើស ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ) ឆ្នាំ ។

១១-ការហាមឃាត់ ការធ្វើអាជីវកម្មបើគ្រឹះស្ថាន ដែលបើកជាសាធារណៈ ឬ ដែលប្រើប្រាស់ដោយសាធារណជនជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥(ប្រាំ) ឆ្នាំ ។

១២-ការបណ្តេញចេញពីទីផ្សាររូលបត្រ ។

១៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេលមិនលើសពី ២(ពីរ) ខែ ។

១៤-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ។

១៥-ការចាក់ផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍សម្រាប់រយៈពេលមិនលើសពី ៨(ប្រាំបី) ថ្ងៃ ។

ROYAUME DU CAMBODGE * LE MINISTRE du PALAIS ROYAL *

**មាត្រា ៥៦.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

ចំពោះបទល្មើសដូចមានចែងក្នុងច្បាប់នេះ នីតិបុគ្គលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះបទល្មើសដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាង ដើម្បីជាប្រយោជន៍នៃនីតិបុគ្គលនោះ ។

ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ ។

**មាត្រា ៥៧.- ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលទោសបន្ថែមមួយ ឬ ច្រើន ដូចខាងក្រោម :

-ការរំលាយចោល

-ការដាក់ឱ្យនៅក្រោមការតាមដានរបស់តុលាការ

-ការហាមចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន

-ការបណ្តេញចេញពីទីផ្សារមូលបត្រ

-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ

-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាគោលដៅនៃបទល្មើស

-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស

-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស

-ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការចាក់ផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយគមនាគមន៍ សោតទស្សន៍ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១០

# អវសានប្បញ្ញត្តិ

**មាត្រា ៥៨.- បទប្បញ្ញត្តិដែលផ្ទុយនឹងច្បាប់នេះ**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៧១០.៥៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ: ៥០២ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៧

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ

- **ការកាន់កាប់ភាគហ៊ុនចំនួនច្រើន** (Substantial Share Holding) សំដៅដល់ការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់បុគ្គលម្នាក់ ឬ ភាគីពាក់ព័ន្ធ ឬ សមាការីរបស់បុគ្គលនោះដែលមានចំនួនចាប់ពី ៥(ប្រាំ) ភាគរយឡើងទៅ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ។

- **កិច្ចសន្យាធានាទិញ** (Underwriting Agreement) សំដៅដល់កិច្ចព្រមព្រៀងដែលធ្វើឡើងដើម្បីធានាទិញមូលបត្រទាំងអស់ ឬ មួយផ្នែកដែលលក់មិនអស់ តាមនីតិវិធីនៅកាលបរិច្ឆេទផុតកំណត់នៃសំណើលក់ជាសាធារណៈ ។ កិច្ចសន្យាធានាទិញនោះគឺរាប់បញ្ចូលទាំងកិច្ចសន្យាធានាទិញបន្តដែលធ្វើឡើងដោយបុគ្គលដែលមានការអនុញ្ញាតតាមច្បាប់នេះ ។

ផុតរយៈពេលនោះឯកជនត្រូវផ្ទេរនូវសិទ្ធិ សិទ្ធិកាន់កាប់ និងផលប្រយោជន៏ទាំងអស់លើសំណង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈល្អ តាមលក្ខខណ្ឌនៃកិច្ចសន្យាមកឱ្យស្ថាប័នមានសមត្ថកិច្ចវិញ ។

- **ក្រុមហ៊ុនមូលបត្រ** (Securities Firm) សំដៅដល់ក្រុមហ៊ុន ឬក្រុមហ៊ុនសហកម្មសិទ្ធិដែលទទួលបានអាជ្ញាប័ណ្ណដើម្បីធ្វើអាជីវកម្មមូលបត្រដោយស្របទៅតាមច្បាប់នេះ ។

- **ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** (Public Limited Company) សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ។

- **ក្រុមហ៊ុនសហកម្មសិទ្ធិ** (Partnertship) សំដៅដល់សមាគមជំនួញ ដែលធ្វើអាជីវកម្មទទួលខុសត្រូវទូទៅ ឬ ទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គលរួមគ្នា និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

- **ក្រុមហ៊ុន** (Company) សំដៅដល់ក្រុមហ៊ុនឯកជន ឬ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបានបង្កើត ឬ ចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- **គណៈកម្មការមូលបត្រកម្ពុជា** (Securities and Exchange Commission of Cambodia) សំដៅដល់នីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់នេះ ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការមូលបត្រ ។

- **តុលាការ** (Court) សំដៅដល់តុលាការមានសមត្ថកិច្ចដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីបើកសវនាការនិងសម្រេចសេចក្តីដែលបណ្តឹងតាមច្បាប់នេះ ។

- **ភ្នាក់ងារក្រុមហ៊ុនមូលបត្រ** (Securities representative) សំដៅដល់បុគ្គលដែលបំពេញនូវមុខងារ ឬ សកម្មភាពតាមការឯកភាពរបស់ក្រុមហ៊ុនមូលបត្រដែលតម្រូវឱ្យ មាន និងត្រូវមានអាជ្ញាប័ណ្ណដោយអនុលោមតាមច្បាប់នេះ ។ ភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវរាប់បញ្ចូលទាំងអគ្គនាយក នាយក បុគ្គលិក ឬ នយោជិតរបស់ក្រុមហ៊ុន ឬ សហកម្មសិទ្ធិករដែលបំពេញមុខ-ងារទាំងនេះក្នុងនាមក្រុមហ៊ុនមូលបត្រ ។

- **ទីផ្សារមូលបត្រ** (Securities Market) សំដៅដល់ទីផ្សារ ឬ ទីកន្លែងជួញដូរមូលបត្រ ឬ ប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬ ស្នើការទិញ-លក់មូលបត្រ ។

- **ទម្រង់អរូបីនៃមូលបត្រ** (Dematerialized Form) សំដៅដល់ទម្រង់កត់ត្រាកម្មសិទ្ធិស្របច្បាប់នៃមូលបត្រដែលធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ឌីជីថល ឬ កុំព្យូទ័រ ដែលអាចបើកមើលបាននិងបោះពុម្ពជាទម្រង់ដែលអាចអានបាន ។

- **ទិញ** សំដៅដល់ការទិញតាមគ្រប់រូបភាព ដូចជាទិញដោយផ្ទាល់ ឬ ទិញតាមប្រព័ន្ធអេឡិចត្រូនិច ឬ ចុះឈ្មោះសុំទិញ (ធ្វើបរិវិសកម្ម) ។

- **នីតិបុគ្គលប្រតិស្រុត** (Permitted Entity) សំដៅដល់នីតិបុគ្គលដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយនិងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់នេះ និងបទប្បញ្ញត្តិផ្សេងៗ ។ នីតិបុគ្គលនេះមិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា ។

- **បុគ្គល** (Person) សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលរួមទាំងក្រុមហ៊ុននិងក្រុមហ៊ុនសហកម្មសិទ្ធិ ។

- **បុគ្គលពាក់ព័ន្ធ** (Related Entity) ទាក់ទិននឹងក្រុមហ៊ុនដែលធ្វើសំណើលក់មូលបត្រជាសាធារណៈសំដៅដល់បុគ្គលណាមួយដូចខាងក្រោម :

ក-ភាគទុនិកដែលជាស្ថាបនិកក្រុមហ៊ុន ។

ខ-សាច់ញាតិផ្ទាល់របស់ភាគទុនិកជាស្ថាបនិកក្រុមហ៊ុន ។

គ-នាយកក្រុមហ៊ុន ឬ សាខាក្រុមហ៊ុន ឬ ក្រុមហ៊ុនហូលឌីង ។

ឃ-សាច់ញាតិផ្ទាល់របស់នាយកក្រុមហ៊ុនទាំងនោះ ។

ង-សាខាក្រុមហ៊ុន ឬ ក្រុមហ៊ុនហូលឌីង ឬ សាខាក្រុមហ៊ុនហូលឌីង ។

ច-រូបវន្តបុគ្គលឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានចែងក្នុងបទប្បញ្ញត្តិ ឬ អនុក្រឹត្យ ។

- **ប្រតិបត្តិកររក្សាទុកមូលបត្រ** (Securities Depository) សំដៅដល់បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀត ដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្មដូចខាងក្រោមនេះ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬ ធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ :

ក- កាន់កាប់ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ក្នុងនាមអតិថិជន ឬ បុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង ។

ខ-ទទួលរក្សាទុកនូវមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬ ជាទម្រង់អរូបីក្តីដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រក្នុងនាមអតិថិជនឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង ។

គ-ផ្តល់សេវាកម្មនិងលក្ខណៈងាយស្រួលផ្សេងៗទៀតដែលទាក់ទិននឹងការផ្តល់សេវាកម្មដូចមានចែងក្នុងកថាខណ្ឌ(ក) និង(ខ) ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

- **ប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម** (Exempt Securities Transaction) សំដៅដល់ប្រតិបត្តិការមូលបត្រដែលធ្វើដោយបុគ្គលជាក់លាក់ណាមួយ ឬ ដោយបុគ្គលផ្សេងទៀត ដើម្បីចុះឈ្មោះ ស៊ុំទិញ ទិញ បោះផ្សាយ លក់ ឬ ផ្ទេរមូលបត្រ ដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ ។

- **ប្រព័ន្ធផាត់ទាត់ និងទូទាត់** (Clearance and Settlement Facility) សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្របំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកបានដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ ។

- **ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម** (Interest in a Managed Investment Scheme) សំដៅដល់ផលប្រយោជន៍ស្របច្បាប់ទោះបីដោយផ្ទាល់ ឬ ដោយប្រយោល នៅក្នុងគម្រោងវិនិយោគដែលមានលក្ខណៈដូចតទៅ :

១-បុគ្គលផ្តល់វិភាគទានសាច់ប្រាក់ ឬ ផ្តល់វត្ថុមានតម្លៃ ដើម្បីមានសិទ្ធិទទួលផលកម្រៃដែលបានមកពីគម្រោងវិនិយោគ ។

២-រាល់វិភាគទានដែលប្រមូលបានហើយត្រូវបានយកទៅប្រើប្រាស់នៅក្នុងគម្រោងវិនិយោគ ដើម្បីបង្កើតផលកម្រៃហិរញ្ញវត្ថុ ឬ ផលកម្រៃដែលបានមកជាសិទ្ធិ ឬ ជាផលប្រយោជន៍លើទ្រព្យសម្បត្តិ សម្រាប់សមាជិកដែលមានផលប្រយោជន៍ក្នុងគម្រោងវិនិយោគនោះ ទោះបីសមាជិកនោះមិនគ្រប់គ្រងលើប្រតិបត្តិការប្រចាំថ្ងៃនៃគម្រោងវិនិយោគនោះក៏ដោយ ។

- **ពាណិជ្ជករមូលបត្រ** (Securities Dealer) សំដៅដល់ពាណិជ្ជករដែលធ្វើអាជីកម្មមូលបត្រ ។

- **ពាណិជ្ជករមូលបត្រអញ្ញត្រកម្ម** (Exempt Securities Dealer) សំដៅដល់បុគ្គលដែលធ្វើអាជីវកម្មមូលបត្រ ដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ ។ ពាណិជ្ជករមូលបត្រអញ្ញត្រកម្មនេះនឹងមានចែងដោយអនុក្រឹត្យ ឬ ប្រកាស ។

- **ភាគហ៊ុនមានសិទ្ធិបោះឆ្នោត** (Voting Share) សំដៅដល់ភាគហ៊ុនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលផ្តល់សិទ្ធិបោះឆ្នោតទៅឱ្យអ្នកកាន់កាប់ភាគហ៊ុនដែលបានចុះបញ្ជី ។

- **មូលបត្រមហាជន** (Non-government Securities) សំដៅដល់មូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលផ្សេងទៀត ដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអនុលោមតាមច្បាប់ ។ មូលបត្រទាំងនោះមាន :

ក-មូលបត្រកម្មសិទ្ធិរាប់បញ្ចូលទាំងភាគហ៊ុន ។

ខ-មូលបត្របំណុល រាប់បញ្ចូលទាំងសញ្ញាប័ណ្ណ ។

គ-ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម ។

ឃ-ឧបករណ៍និស្សន្ទ ឬ ឧបករណ៍ដេរីវេទីវ ដែលទាក់ទងនឹងមូលបត្រមួយគឺយោងទៅលើចំណុច(ក) (ខ) ឬ (គ) ខាងលើ ។

ង-ឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដែលកំណត់ថាជាមូលបត្រ ។

- **មូលបត្រកម្មសិទ្ធិ** (Equity Securities) សំដៅដល់ផលប្រយោជន៍ ឬ សិទ្ធស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលបរទេសប្រហាក់ប្រហែលហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោតភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា ។

- **មូលបត្រគារវាហក** (Bearer Securities) សំដៅដល់មូលបត្រដែលកម្មសិទ្ធិនៃមូលបត្រនោះត្រូវបានកំណត់ដោយការកាន់កាប់ជារូបវន្ត មិនមែនតាមរយៈការចុះបញ្ជីនៃកម្មសិទ្ធិករនៅក្នុងបញ្ជីមូលបត្រ ដែលរក្សាទុកដោយ ឬ រក្សាទុកសំរាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ។

- **មូលបត្រថ្មី** (New Securities) សំដៅដល់មូលបត្រដែលមិនធ្លាប់បានបោះផ្សាយ ឬ ធ្វើសំណើលក់ជាសាធារណៈពីមុនមកដោយក្រុមហ៊ុនបោះផ្សាយមូលបត្រដែលមានចែងក្នុងផ្សាយ ។

- **មូលបត្របំណុល** (Debt Securities) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយ ដោយបញ្ជាក់ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឱ្យប្រាក់ខ្ចី ឬ ដាក់ជាប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬ បុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះ ហើយទោះបីជាមាន ឬ គ្មានទ្រព្យដាក់ធានាក្តី ។

- **រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- **វិធានប្រតិបត្តិការនៃទីផ្សារមូលបត្រ ឬ នៃប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ នៃសេវារក្សាទុកមូលបត្រ** (Operating Rules of a securities market, clearance and settlement facility, or Securities Depository) សំដៅដល់វិធាន និងនីតិវិធី ដែលគ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សារ ឬ ប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ សេវារក្សាទុកមូលបត្រ ដែលរួមទាំង :

(១)លក្ខន្តិកៈរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ឬ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ ។

(២)វិធាននៃការចុះបញ្ជីនៅទីផ្សារមូលបត្រ ។

- **សមាភាវី** (Associate) សំដៅដល់បុគ្គលដែលកំពុងមានទំនាក់ទំនងអាជីវកម្មជាមួយបុគ្គលមួយផ្សេងទៀត ។

- **សមាជិកគ្រួសារផ្ទាល់** (Close relative) សំដៅដល់ទំនាក់ទំនងជាប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស ឬ បងប្អូនស្រីរបស់បុគ្គលណាម្នាក់ ។

- **ស្វ័យនិយ័តករ** (Self Regulatory Organization) សំដៅដល់ស្ថាប័នដែលគ្រប់គ្រងសមាជិករបស់ខ្លួនតាមរបៀបដែលសមាជិកនោះធ្វើអាជីវកម្ម ។

- **សំណងព្យសនកម្ម** (Damage) សំដៅដល់ការទូទាត់សងការខូចខាត ។

- **សំណើលក់មូលបត្រជាសាធារណៈ** (Public Offer) សំដៅដល់ការអញ្ជើញសាធារណជនឱ្យដាក់ពាក្យសុំទិញ ឬ ទិញមូលបត្រ ។ សំណើលក់នេះរួមមាន :

(១) សំណើដាក់លក់ ឬ ទិញមូលបត្រដែលធ្វើឡើងចំពោះមជ្ឈដ្ឋានសាធារណជនជាក់លាក់ណាមួយដែលត្រូវបានជ្រើសរើសឡើងតាមរបៀបណាក៏ដោយ

(២)សំណើដាក់លក់ឬ ទិញមូលបត្រដែលធ្វើឡើង តាមរបៀបចៃដន្យចំពោះសមាជិកនៃមជ្ឈដ្ឋានសាធារណៈដែលបានជ្រើសរើស

(៣)សំណើដាក់លក់ ឬ ទិញមូលបត្រដែលធ្វើឡើង ចំពោះបុគ្គលដែលស្គាល់ពីមុនតាមរយៈការផ្សាយពាណិជ្ជកម្មសំណើដាក់លក់ ឬ ទិញ ឬ តាមរយៈការអញ្ជើញបុគ្គលនោះឱ្យមកសាកសួរព័ត៌មាន ឬ សុំការពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ

(៤)ការចែកអត្ថបទផ្សាយពាណិជ្ជកម្ម ឯកសារផ្តល់ព័ត៌មាន ឬពាក្យស្នើសុំដែលទាក់ទងនឹងការដាក់ពាក្យសុំទិញ ការទិញ ឬ ការលក់មូលបត្រ ។

ប៉ុន្តែសំណើលក់ជាសាធារណៈមិនរាប់បញ្ចូលនូវ :

-សំណើលក់ជាឯកជនដែលធ្វើឡើងចំពោះបុគ្គលដែលមានទំនាក់ទំនងជាមួយនឹងបុគ្គលធ្វើសំណើលក់ ឬ សហការី ។

-សំណើលក់ជាឯកជនដែលធ្វើឡើង ចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប)រូប ។

-ការអញ្ជើញបុគ្គលណាមួយឱ្យធ្វើកិច្ចព្រមព្រៀងធានាទិញ ឬ កិច្ចព្រមព្រៀងធានាបន្តដែលទាក់ទិននឹងការបោះផ្សាយមូលបត្រ ។

- **សំណើលក់មូលបត្រជាឯកជន** (Private or personal Offer) សំដៅដល់សំណើលក់ដែល :

១-ត្រូវបានធ្វើស្ទីការដោយបុគ្គលដែលជាអ្នកទទួលសំណើ ។

២-ត្រូវបានធ្វើឡើងចំពោះបុគ្គល ដែលមានការចាប់អារម្មណ៍ចំពោះសំណើលក់ដោយពិចារណាលើ

(ក)ទំនាក់ទំនងពីមុនរវាងបុគ្គលដែលធ្វើសំណើ និងអ្នកដែលទទួលសំណើនោះ

(ខ)ទំនាក់ទំនងវិជ្ជាជីវៈឬទំនាក់ទំនងដទៃទៀតរវាងបុគ្គលដែលធ្វើសំណើ និងអ្នកទទួលសំណើនោះ

(គ)សេចក្តីប្រកាស ឬ អំពើរបស់បុគ្គលណាមួយដែលបង្ហាញថាខ្លួនចាប់អារម្មណ៍នឹងសំណើនោះ ។

- **សំណើលក់អញ្ញត្រកម្ម** (Exempt Offer) សំដៅដល់សំណើលក់មូលបត្រជាសាធារណៈ ដោយមិនចាំបាច់បំពេញតាមលក្ខខណ្ឌនៃច្បាប់ ។ សំណើលក់អញ្ញត្រកម្មនេះមានចែងដោយអនុក្រឹត្យឬប្រកាស ។

- **អសាធនីយ** (Insolvent) សំដៅដល់ការមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់សងបំណុលដែលជំពាក់គេ ។

- **អ្នកវិនិយោគសាធារណៈ** (Public Investor) សំដៅដល់សាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិទិញឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសមាការី ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ នីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតនោះ ។

- **អាជីវកម្មមូលបត្ររបស់បុគ្គលមួយ** (Securities Business of Person) ត្រូវគិតទាំងសកម្មភាពដូចខាងក្រោម :

ក-ការទិញ ឬលក់មូលបត្រក្នុងនាមជាភ្នាក់ងាររបស់បុគ្គលផ្សេងទៀត ។

ខ-ការទិញ ឬ លក់មូលបត្រដោយប្រើប្រាស់មូលនិធិរបស់ខ្លួន និងក្នុងនាមខ្លួនឯង ។

គ-ការផ្តល់ប្រឹក្សាអំពីវិនិយោគមូលបត្រ ឬ ការបោះផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនអ្នកវិនិយោគសាធារណៈ ។

ឃ-ចុះកិច្ចព្រមព្រៀងធានា ជាមួយក្រុមហ៊ុនដែលធ្វើសំណើលក់ ឬ ទិញមូលបត្រ ឬ ចុះកិច្ចព្រមព្រៀងធានាទិញ ឬ លក់បន្ត ។

- **ឯកសារផ្តល់ព័ត៌មានជាប្រចាំ** (Continuous Disclosure Document) សំដៅដល់ឯកសារផ្តល់ព័ត៌មានដែលពិពណ៌នាអំពីព្រឹត្តិការណ៍ ដែលកើតឡើងនៅពេលណាមួយក្នុងអាយុកាលរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុត ។

- **ឯកសារផ្តល់ព័ត៌មាន** (Disclosure Document) សំដៅដល់លិខិតជូនដំណឹង ឬ សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលអធិប្បាយអំពីប្រវត្តិក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុ ឬជាការអញ្ជើញឱ្យទិញ ឬ សំណើឱ្យគេដាក់ពាក្យសុំទិញ ឬ ទិញមូលបត្រ ឬប្រកាសអំពីការដាក់លក់ ឬ ការលក់មូលបត្រ និងរាប់បញ្ចូលទាំងឯកសារផ្តល់ព័ត៌មានជាប្រចាំ ឬ ឯកសារផ្តល់ព័ត៌មានជំនួសផងដែរ ។

- **ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ** (Derivative Instrument) សំដៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬ កាតព្វកិច្ចនៃមូលបត្រដើមទៅឱ្យបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬ កាតព្វកិច្ចទិញលក់ ឬ ដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគតដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬ មិនប្រើប្រាស់សិទ្ធិនេះក៏ដោយ ។